ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ
ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស
ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

លេខ : ០០១.ណ.ណ.ន [illegible]

ភ្នំពេញ, ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨

# គោលការណ៍ណែនាំ ស្តីពីការអនុវត្តច្បាប់ស្តីពី
# ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

(៤)

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា :

-អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

-រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬ កាមគុណលើកុមារ ។

-ផ្តើមចេញពីបញ្ញត្តិខាងលើនេះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានលក្ខណៈសម្បត្តិពេញលេញ ត្រូវបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥/ ០២/០៨ ។

-ច្បាប់មួយដែលចូលជាធរមានហើយ ប្រជាពលរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ទោះស្ថិតនៅក្នុងអំណាចណាក៏ដោយ ត្រូវតែមានកាតព្វកិច្ចគោរពនិងអនុវត្តតាម ជាពិសេសអាជ្ញាធរដែលមានសមត្ថកិច្ចអនុវត្តផ្ទាល់ត្រូវតែយកចិត្តទុកដាក់យល់ដឹងអោយបានច្បាស់លាស់ ដើម្បីធានាដល់ការអនុវត្តអោយមានប្រសិទ្ធិភាព តម្លាភាព និងយុត្តិធម៌ ។

-ដើម្បីធានាដល់ការអនុវត្តច្បាប់នេះ ក្រុមការងារដឹកនាំប្រឆាំងអំពើជួញដូរមនុស្ស ដាក់ចេញគោលការណ៍ណែនាំមួយចំនួនដល់សមត្ថកិច្ចនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចត្រូវធ្វើប្រតិបត្តិការបង្ក្រាបអំពើល្មើស ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះ ដែលមានអត្ថន័យដូចខាងក្រោម :

## I.គោលការណ៍ទូទៅ :

**១-មុនធ្វើប្រតិបត្តិការបង្ក្រាប** ត្រូវធ្វើការស្រាវជ្រាវ ស៊ើបអង្កេតអោយបានច្បាស់លាស់ពីអំពើ និងសកម្មភាព ព្រមទាំងភស្តុតាងដែលពាក់ព័ន្ធដល់មុខសញ្ញានៃបទល្មើសនីមួយៗ ។

**២-រាល់គ្រប់ប្រតិបត្តិការបង្ក្រាប** ត្រូវតែរាយការណ៍សុំយោបល់ពីព្រះរាជអាជ្ញា ក្នុងសមត្ថកិច្ចដែនដីដើម្បីទទួលបានការដឹកនាំណែនាំ និងសម្របសម្រួលដល់កិច្ចប្រតិបត្តិការ ។

**៣-រាល់ការឆែកឆេរទីតាំងស្វែងរកជនជាប់សង្ស័យ និងប្រមូលភស្តុតាង** ត្រូវគោរពអោយបានម៉ឺងម៉ាត់ទៅតាមគោលការណ៍ដែលច្បាប់បានកំណត់ ។ រាល់វត្ថុតាងដែលប្រមូលបានត្រូវធ្វើកំណត់ហេតុអោយបានច្បាស់លាស់ និងត្រឹមត្រូវ សំភារៈដែលដកហូត ទោះជាបណ្តោះអាសន្នក្តី ក៏ត្រូវតែមានកំណត់ហេតុអោយបានច្បាស់លាស់ និងត្រឹមត្រូវផងដែរ ។

**៤-បុគ្គលពេស្យាចារត្រូវចាត់ទុកជាជនរងគ្រោះ** នៃអំពើសញ្ញារកម្ម ។ អំពើពេស្យាចារមិនមែនជាបទល្មើសទេ ។ ដូច្នេះអ្នកប្រកបរបរពេស្យាចារផ្ទាល់ខ្លួន ពុំត្រូវទទួលការផ្តន្ទាទោសនោះឡើយ ។

## II. គោលការណ៍ច្បាប់ :

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលដៅជាមូលដ្ឋានចំនួនពីរច្បាស់លាស់គឺ :

**១-បង្ក្រាបអំពើជួញដូរមនុស្ស**

**២-បង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ**

ដូច្នេះហើយអ្នកអនុវត្តច្បាប់ ជាពិសេសអាជ្ញាធរមានសមត្ថកិច្ចក្នុងការបង្ក្រាបបទល្មើសនេះ ត្រូវមានការយល់ដឹងឱ្យបានច្បាស់លាស់ពីគោលដៅនីមួយៗ ទើបធានាបាននូវការបង្ក្រាបប្រកបដោយប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌ ។

**ក-អំពើជួញដូរមនុស្ស :**

ជាបទល្មើសដែលមានភាពស្មុគស្មាញ ហើយរួមផ្សំទៅដោយអំពើជាច្រើន ទើបអាចសំរេចផលដែលតាមពិធីសាររបស់អង្គការសហប្រជាជាតិ អំពើជួញដូរមនុស្សកើតឡើងបានត្រូវឆ្លងកាត់នូវដំណាក់កាលបីគឺ **ដំណាក់កាលជ្រើសរើស ដំណាក់កាលបំលាស់ទី** និង **ដំណាក់កាលធ្វើអាជីវកម្ម** ។ នៅតាមដំណាក់កាលនីមួយៗ អាចមានអំពើរួមផ្សំផ្សេងៗទៀតតាមស្ថានភាព និងកាលៈទេសៈ ។

តាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានដាក់អំពើរួមផ្សំទាំងឡាយនៃអំពើជួញដូរមនុស្សតាមពិធីសារអន្តរជាតិ ទៅជាបទល្មើសដោយឡែកៗពីគ្នា ដើម្បីមានភាពងាយស្រួលក្នុងការអនុវត្ត និងផ្តន្ទាទោសអោយស្រប និងមានតុល្យភាពទៅនឹងអំពើដែលបានប្រព្រឹត្តជាអាទិ៍ :

**អំពើដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដោយផ្ទាល់ជាអាទិ៍ :**

១-អំពើលក់-ដូរមនុស្ស

២-អំពើលក់-ដូរមនុស្សដោយមានគោលដៅស្វែងរកប្រយោជន៍

៣-អំពើលក់-ដូរមនុស្សសំរាប់នាំឆ្លងដែន

**បន្ថែមនេះនៅមានអំពើរួមផ្សំមួយចំនួនទៀតជាអាទិ៍ :**

១-ការនាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅស្វែងរកប្រយោជន៍

២-ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច

៣-ការដឹកជញ្ជូនដោយមានគោលដៅស្វែងរកប្រយោជន៍

៤-ការទទួលយកមនុស្សដោយមានគោលដៅស្វែងរកប្រយោជន៍

អំពើទាំងបួនខាងលើ ជាបទល្មើសរួមផ្សំ ហើយមានលក្ខណៈ និង ទម្រង់ដូចជាអំពើជួញដូរមនុស្សដោយផ្ទាល់ ។ ក្រៅពីនេះនៅមានអំពើផ្សេងទៀត ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដែរជាអាទិ៍ :

១-ការនាំយកមនុស្សចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន

២-អំពើនាំឆ្លងដែន

៣-ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស

៤-ការបង្ខាំងមនុស្សដោយខុសច្បាប់

ដូច្នេះអាជ្ញាធរដែលមានសមត្ថកិច្ច បង្ក្រាបអំពើជួញដូរមនុស្ស ត្រូវយកចិត្តទុកដាក់ស្វែងរកបទល្មើសទាំងអស់ដែលពាក់ព័ន្ធ ។

ដើម្បីធានាដល់ការបង្ក្រាបអំពើល្មើសទាំងអស់នោះ គប្បីត្រូវយល់ដឹងអំពីធាតុផ្សំ នៃអំពើល្មើសនីមួយៗដែលមានចែងក្នុងច្បាប់អោយបានច្បាស់លាស់ ព្រោះថានេះជាមូលដ្ឋានក្នុងការស្វែងរកភស្តុតាង ដើម្បីឈានដល់ការចាប់ខ្លួនជនសង្ស័យ និងជួយសង្គ្រោះដល់ជនរងគ្រោះ ។



អគ្គស្នងការដ្ឋាននគរបាលជាតិ និពន្ធដោយមូលក្បាលផ្ទាល់ ជូនពេញឆ្មម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន Fax-Phone : 023 720 333 E-mail : Bith.kimhong@yahoo.com

**ខ-អំពើធ្វើអាជីវកម្មផ្លូវភេទ**

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានកំណត់នូវអំពើដែលទាក់ទងនឹងភេទមួយចំនួនថា ជាបទល្មើសជាអាទិ៍ :

**១-អំពើសញ្ចារកម្ម :**

ច្បាប់បានកំណត់នូវអំពើមួយចំនួនថាជាអំពើសញ្ចារកម្មជាអាទិ៍ :

-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

-ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ

-ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយអោយធ្វើអំពើពេស្យាចារ

-ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីអោយបុគ្គលនោះធ្វើពេស្យាចារ

ដូច្នេះដើម្បីបង្ក្រាបអំពើសញ្ចារកម្ម អាជ្ញាធរមានសមត្ថកិច្ច ត្រូវស្វែងរកអោយឃើញ នូវអំពើណាមួយក្នុងចំណោមអំពើទាំង៤ ខាងលើនេះ ហើយក៏ត្រូវយល់ដឹងអោយបានច្បាស់ពីធាតុផ្សំ នៃអំពើនីមួយៗ ដែលបានកំណត់នៅក្នុងច្បាប់នឹងត្រូវរកភស្តុតាងបញ្ជាក់ផងដែរ ទើបធានាដល់ការចោទប្រកាន់ ។

ក្រៅពីនេះនៅមានអំពើមួយចំនួនទៀត ដែលច្បាប់នេះបានចាត់ទុកថាដូចគ្នានឹងសញ្ចារកម្មដែរជាអាទិ៍ :

-អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ អោយលាភការដល់ពេស្យាចារជនដទៃ ។

-អំពើរបស់ជនណាដែលបានជួយសម្រួល ឬ បិទបាំងនូវធនធានដែលខ្លួនបានដឹង ថាបានមកពីអំពើសញ្ចារកម្ម។

-អំពើរាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងជាគុណប្រយោជន៍ ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើ ពេស្យាចារ ។

ដូច្នេះបើមានអំពើណាមួយខាងលើនេះ ត្រូវរកឃើញនោះ ត្រូវចាត់ទុកជាអំពើសញ្ចារកម្ម ហើយជនដែលប្រព្រឹត្តត្រូវតែទទួលទោសតាមច្បាប់ ។

**២-អំពើពេស្យាចារ :**

ច្បាប់ពុំបានកំណត់ថាមុខរបរពេស្យាចារជាបទល្មើសនោះទេ ។ ដូច្នេះជនណាដែលប្រកបរបរពេស្យាចារ គឺពុំត្រូវបានផ្តន្ទាទោសនោះឡើយ ។ ប៉ុន្តែច្បាប់នេះបានកំណត់អំពើមួយចំនួនដែលពាក់ព័ន្ធជាមួយ នឹងមុខរបរនេះថាជាបទល្មើសជាអាទិ៍ :

-ការដឹកនាំពេស្យាចារ

-ការដឹកនាំគ្រឹះស្ថានពេស្យាចារ

-ការផ្តល់ទីកន្លែងសំរាប់ធ្វើពេស្យាចារ

-ការទិញពេស្យាចារកុមារ

-អំពើអូសទាញពេស្យាចារកុមារ

-ការអោយខ្ចីប្រាក់ដោយមានល័ក្ខខ័ណ្ឌទាក់ទងនឹងពេស្យាចារកុមារ

-កិច្ចសន្យា នៃពេស្យាចារកុមារ

**៣-រូបភាព និង សម្ភារៈអាសអាភាស :**

ច្បាប់បានកំណត់អំពើមួយចំនួនដែលពាក់ព័ន្ធនឹងរូបភាពនិងសម្ភារៈអាសអាភាស ថាជាបទល្មើសជាអាទិ៍:



អគ្គស្នងការដ្ឋាននគរបាលជាតិ ជិតរង្វង់មូលក្បាលថ្នល់ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន Fax-Phone : 023 720 333 E-mail : Bith.kimhong@yahoo.com

-ការចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈនូវរូបភាព និង សម្ភារៈអាសអាភាស ។

-ការផលិត ការកាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវរូបភាព និង សម្ភារៈអាសអាភាស ក្នុងគោលដៅ ចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈ ។

**៤-អំពើអាសគ្រាមនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ :**

ច្បាប់បានកំណត់អំពើមួយចំនួន ដែលទាក់ទងនឹងភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ថាជាបទល្មើសជាអាទិ៍ :

-ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ។

-អំពើ នៃការប៉ះពាល់ ឬ បង្ហាញកេរ្តិ៍ភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់អនីតិជនអាយុក្រោម ១៥ឆ្នាំ ឬ អោយអនីតិជនប៉ះពាល់កេរ្តិ៍ភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជនក្នុងចេតនា ធ្វើអោយរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

## III-គោលការណ៍ នៃការបង្ក្រាបបទល្មើស

**១-អំពើជួញដូរមនុស្ស :**

ជាអំពើដែលប៉ះពាល់ដល់សិទ្ធិរស់រានមានជីវិតរបស់មនុស្សយ៉ាងធ្ងន់ធ្ងរ ដែលជាបទល្មើស ត្រូវតែធ្វើការបង្ក្រាបដោយគ្មានករណីលើកលែង ។

ការបង្ក្រាបបទល្មើសជួញដូរមនុស្ស មិនមែនសំដៅលើតែអំពើជួញដូរមនុស្សដោយផ្ទាល់នោះទេ គឺត្រូវយកចិត្តទុកដាក់ទៅលើគ្រប់អំពើរួមផ្សំពាក់ព័ន្ធទាំងអស់ ដូចដែលបានរៀបរាប់ខាងលើ ។

**២-អំពើធ្វើអាជីវកម្មផ្លូវភេទ :**

-គ្រប់អំពើធ្វើអាជីវកម្មផ្លូវភេទទាំងអស់ ដែលបានរៀបរាប់ខាងលើ អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ និងបង្ក្រាបទៅតាមនីតិវិធីច្បាប់ ។

-ដោយឡែក ដើម្បីធានារក្សានូវសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការបង្ក្រាបអំពើសញ្ចារកម្មគប្បីត្រូវផ្អែកលើហេតុការណ៍ជាក់ស្តែងដូចខាងក្រោមនេះ :

- បើមានពាក្យបណ្តឹងពីប្រជាពលរដ្ឋ ដែលរស់នៅជុំវិញទីតាំងនៃអំពើសញ្ចារកម្ម ដែលធ្វើអោយមានការប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ ។
- បើមានបណ្តឹងថាមានជនរងគ្រោះ ត្រូវបានគេបង្ខំអោយប្រកបរបរពេស្យាចារ នៅក្នុងទីតាំងដែលមានអំពើសញ្ចារកម្មនេះ ។
- បើអំពើសញ្ចារកម្មមានប្រើប្រាស់អនីតិជនអោយប្រកបរបរពេស្យាចារ ។
- បើអំពើសញ្ចារកម្មនេះធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ករណីទាំងបួនខាងលើនេះ បើមានករណីណាមួយត្រូវបានរកឃើញ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការទៅតាមនីតិវិធីនៃច្បាប់ ។

បញ្ហា :

បច្ចុប្បន្ននេះអំពើពេស្យាចារ និងអំពើសញ្ចារកម្ម បានកំពុងបង្កប់ខ្លួនភ្ជាប់នឹងសកម្មភាពស្របច្បាប់មួយចំនួនជាអាទិ៍:

**១-សកម្មភាពសេវាកម្មម៉ាស្សា :**

នៅតាមកន្លែងម៉ាស្សាមួយចំនួន អ្នកបំរើសេវាកម្មម៉ាស្សា បានបំរើសេវាផ្លូវភេទផងដែរដល់ភ្ញៀវ ដែលទៅម៉ាស្សាដើម្បីបានកំរៃបន្ថែម ។

តើសកម្មភាពបែបនេះ ជាប់ពាក់ព័ន្ធនឹងអំពើសញ្ជារកម្មដែលឬទេ ចំពោះអ្នកទទួលខុសត្រូវខាងសេវាកម្មម៉ាស្សា ?

ករណីបែបនេះអាចមានការពាក់ព័ន្ធ ឬ គ្មានការពាក់ព័ន្ធទៅតាមស្ថានភាព និងចរិតលក្ខណៈនៃសកម្មភាព និងការទទួលខុសត្រូវដែលមានដូចខាងក្រោម :

-ក្នុងករណីប្រាក់កំរៃដែលបានមកពីសេវាបំរើផ្លូវភេទនេះ ត្រូវបានអ្នកផ្តល់សេវាផ្លូវភេទទទួលដោយផ្ទាល់ ហើយក៏មិនបានបែងចែក ឬ បង់ទៅអោយអ្នកចាត់ចែងគ្រប់គ្រងខាងសេវាម៉ាស្សាទេនោះ អ្នកគ្រប់គ្រងចាត់ចែងនេះ មិនជាប់ពាក់ព័ន្ធនឹងអំពើសញ្ជារកម្មនោះទេ ។

-ផ្ទុយទៅវិញ បើប្រាក់កំរៃដែលបានមកពីសេវាបំរើផ្លូវភេទត្រូវបានបែងចែក ឬ បង់ទៅអោយអ្នកចាត់ចែង គ្រប់គ្រងសេវាម៉ាស្សានោះ អ្នកចាត់ចែងគ្រប់គ្រងនេះ នឹងជាប់ពាក់ព័ន្ធទៅនឹងអំពើសញ្ជារកម្ម ។

-ទន្ទឹមនេះក្នុងករណី អ្នកចាត់ចែង គ្រប់គ្រងពុំបានទទួល ឬ បែងចែកកំរៃ ដែលបានមកពីសេវាផ្លូវភេទនេះទេ ប៉ុន្តែគេបានអោយអ្នកបំរើសេវាផ្លូវភេទនេះបង់ថ្លៃបន្ទប់ និងការប្រើប្រាស់សម្ភារៈក្នុងការរួមភេទ ។ ករណីបែបនេះ គឺជាករណី ដែលផ្តល់កន្លែងអោយគេប្រព្រឹត្តអំពើពេស្យាចារ ដែលនេះគឺជាបទល្មើស ។

**២-សកម្មភាពសេវាកម្មការ៉ាអូខេ :**

ករណីនេះ ក៏មិនខុសគ្នានិងសេវាកម្មម៉ាស្សាដែរ ស្ត្រីដែលបំរើសេវាកម្មការ៉ាអូខេភាគច្រើន គឺបានយល់ព្រមបំរើសេវាផ្លូវភេទ ដើម្បីបានប្រាក់កំរៃបន្ថែម ។

នៅក្នុងសេវាកម្មការ៉ាអូខេ មានការខុសគ្នាបន្តិចពីសេវាកម្មម៉ាស្សា ត្រង់ថាសេវាកម្មបំរើផ្លូវភេទពុំអាចប្រព្រឹត្តទៅបាននៅក្នុងកន្លែងសេវាកម្មការ៉ាអូខេ ដូចសេវាកម្មម៉ាស្សានោះទេ ។ ដូច្នោះការបំរើសេវាផ្លូវភេទត្រូវទៅរកទីតាំងផ្សេងជាអាទិ៍ :

-ការ៉ាអូខេ ដែលមានទីតាំងនៅក្នុងសណ្ឋាគារ ឬ ផ្ទះសំណាក់ :

ក្នុងករណីនេះ បើអ្នកបំរើផ្លូវភេទ អាចប្រើប្រាស់បន្ទប់របស់សណ្ឋាគារ ឬ ផ្ទះសំណាក់នេះ :

- ក្នុងករណី បើអ្នកចាត់ចែង គ្រប់គ្រងសណ្ឋាគារ ឬ ផ្ទះសំណាក់គ្រប់គ្រងទាំងការ៉ាអូខេ ហើយគ្រប់គ្រងទាំងសេវាបំរើផ្លូវភេទផង ដោយទទួលបានកំរៃពីសេវាកម្មផ្លូវភេទនេះ នោះករណីបែបនេះ គឺជាអំពើសញ្ជារកម្ម ។
- ក្នុងករណីសណ្ឋាគារ ឬ ផ្ទះសំណាក់គ្រាន់តែយកថ្លៃជួលបន្ទប់ ករណីបែបនេះ បើសណ្ឋាគារ ឬ ផ្ទះសំណាក់ដឹងថាគេនឹងប្រព្រឹត្តអំពើពេស្យាចារ ហើយនៅតែជួលបន្ទប់អោយទៀត នោះនឹងជាប់ពាក់ព័ន្ធទៅនឹងអំពើ ផ្តល់កន្លែងសំរាប់ប្រព្រឹត្តអំពើពេស្យាចារដែលនេះជាបទល្មើស ។

-ករណីសេវាបំរើផ្លូវភេទនៅក្រៅ ហើយត្រូវចេញមុនពេលម៉ោងបំរើសេវាការ៉ាអូខេ :

ករណីបែបនេះអ្នកបំរើសេវាការ៉ាអូខេ ដែលចេញទៅនោះត្រូវបង់លុយអោយអ្នកគ្រប់គ្រងការ៉ាអូខេ ។ តើករណីនេះ អ្នកគ្រប់គ្រងជាប់ពាក់ព័ន្ធនឹងអំពើសញ្ជារកម្មដែលឬទេ ?

- ករណីនេះ បើលុយដែលបង់អោយនោះជាភាគហ៊ុន ដែលបានមកពីកំរៃនៃសេវាកម្មបំរើផ្លូវភេទនោះ ករណីនេះ គឺជាអំពើសញ្ជារកម្ម ។
- ផ្ទុយទៅវិញ បើលុយដែលបង់អោយនេះ គឺជាការសងតម្លៃពលកម្មដែលអ្នកបំរើសេវាការ៉ាអូខេនេះបំពេញការងារពុំបានគ្រប់ម៉ោងដែលត្រូវធ្វើនោះ ករណីនេះមិនជាប់ពាក់ព័ន្ធនឹងអំពើសញ្ជារកម្មនោះទេ ។

សេវាបំរើផ្លូវភេទបែបនេះ នៅមានជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពសេវាកម្មផ្សេងៗទៀត ដូចជាសេវាកម្មបំរើតាមភោជនីយដ្ឋាន សេវាកម្មលក់ផ្សព្វផ្សាយពាណិជ្ជកម្មស្រាបៀរ សេវាកម្មនៅតាមក្លឹបកំសាន្តនានា ។ល។



Fax-Phone : 023 720 333 E-mail : Rith.kimhong@yahoo.com

ទោះបីយ៉ាងណាក៏ដោយ ករណីបែបនេះដែលជាប់ពាក់ព័ន្ធទៅនឹងបទល្មើសដូចបានបង្ហាញជូនខាងលើ ហើយដែលត្រូវបង្រ្កាបនោះ គប្បីត្រូវពិនិត្យពិចារណាទៅលើហេតុការណ៍ជាក់ស្តែងទាំង៤ចំណុច ដែលបានកំណត់ខាងលើ ព្រោះនេះជាករណីដែលត្រូវដោះស្រាយចំពោះមុខ ក្នុងការអនុវត្តច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

## IV-គោលការណ៍ដោះស្រាយចំពោះជនរងគ្រោះ

ជនរងគ្រោះដែលជួយសង្គ្រោះបានពីគ្រប់ករណីទាំងអស់ត្រូវថែរក្សា និងគោរពសិទ្ធិរបស់ពួកគេអោយបានល្អ និងត្រឹមត្រូវ ព្រោះពួកគេត្រូវបានរងគ្រោះ គឺមិនត្រូវអោយពួកគេមករងគ្រោះទៀតទេ ដូច្នោះគប្បីត្រូវចាត់វិធានការដូចខាងក្រោមនេះ :

-បន្ទាប់ពីជួយសង្គ្រោះហើយ ការសម្ភាសន៍យកព័ត៌មានពីជនរងគ្រោះ ត្រូវធ្វើជាបន្ទាន់ និងអោយបានឆាប់បំផុត មិនគប្បីអូសបន្លាយពេលវេលា ដោយបង្ខាំងជនរងគ្រោះទុកនៅកន្លែងនគរបាលយុត្តិធម៌អោយយូរពេកនោះទេ។

-បន្ទាប់ពីសម្ភាសន៍រួចហើយ ជនរងគ្រោះត្រូវបញ្ជូនចេញពីកន្លែងនគរបាលយុត្តិធម៌ ដោយបែងចែកទៅតាមស្ថានភាព និងចរិកលក្ខណៈរបស់ជនរងគ្រោះដូចខាងក្រោម :

**១-បើជនរងគ្រោះជាអនីតិជន** ត្រូវប្រគល់អោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយត្រូវផ្តល់ព័ត៌មានទៅអោយឪពុកម្តាយ អ្នកអាណាព្យាបាល ឬ អ្នកទទួលខុសត្រូវស្របច្បាប់លើអនីតិជន ។

**២-បើជនរងគ្រោះជានីតិជន** ត្រូវផ្អែកលើការយល់ព្រម :

-បើពួកគេយល់ព្រម ត្រូវប្រគល់ទៅអោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

-បើពួកគេមិនយល់ព្រម ត្រូវអនុញ្ញាតិអោយពួកគេវិលត្រឡប់ទៅលំនៅស្ថានរបស់ពួកគេវិញ។

**៣-ទ្រព្យសម្បត្តិ សម្ភារៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ** ដែលត្រូវបានដកហូត ត្រូវប្រគល់អោយពួកគេវិញ។

**៤-ការប្រគល់ជនរងគ្រោះទៅអោយមន្ទីរសង្គមកិច្ច** អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ការអនុញ្ញាតអោយជនរងគ្រោះវិលត្រលប់ទៅលំនៅស្ថានវិញ ត្រូវមានកំណត់ហេតុ ហើយកំណត់ហេតុនេះត្រូវដាក់ក្នុងសំណុំរឿងបញ្ជូនទៅអោយព្រះរាជអាជ្ញា ។

ទទួលបានគោលការណ៍ណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់ អនុវត្តច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទអោយបានម៉ឺងម៉ាត់ និងមានប្រសិទ្ធិភាពតាមការណែនាំនេះ ។/.

**ប្រធានក្រុមការងារដឹកនាំ ប.ជ.រ.ព.ត**

**សរ ខេង**



អគ្គស្នងការដ្ឋាននគរបាលជាតិ ជិតវង់មូលក្បាលថ្នល់ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន Fax-Phone : 023 720 333 E-mail : Bith.kimhong@yahoo.com